# អរិយធម៌ Sarazm

**Sarazm** គឺជាស្ថានីយបុរាណវិទ្យា និងជាអរិយធម៌ចំណាស់មួយកន្លែងដែលអ្នកស្រាវជ្រាវបានដឹងថា ជាកន្លែងដែលមនុស្សមកតាំងទីរស់នៅដំបូងៗនៅក្នុងតំបន់អាស៊ីកណ្ដាល (Asia Central)។ បច្ចុប្បន្នស្ថានីយនេះ ស្ថិតនៅភាគពាយ័ព្យ ក្បែរខេត្ត ផានចាខេន (Panjakent) នៃប្រទេសតាជីគីស្ថាន (Tajikistan) និងស្ថិតនៅក្បែរនឹងប្រទេសអ៊ូសបេគីស្ថាន (រូបលេខ១-២)។ តាមរយៈវត្ថុសិល្បៈដែលបានរកឃើញនៅតំបន់នោះ បានបង្ហាញឱ្យឃើញពីតឹកតាងនៃការតាំងទីរស់នៅរបស់មនុស្សនៅស្ថានីយនេះ តាំងពី៤០០០ឆ្នាំមុនគ.សមកម្ល៉េះ។[១]

ស្ថានីយបុរាណវិទ្យានេះត្រូវបានរកឃើញ និងកំណាយចាប់ពីឆ្នាំ១៩៧៧មក ដោយវិទ្យាស្ថានស្រាវជ្រាវជាតិនៃប្រទេសតាជីគីស្ថាន និងបន្តបន្ទាប់មកមានអ្នកស្រាវជ្រាវបរទេសផ្សេងៗទៀតបានមកកំណាយស្រាវជ្រាវនៅតំបន់នៃស្ថានីយនេះ។ តាមរយៈការស្រាវជ្រាវនៅទីតាំងនេះ អ្នកស្រាវជ្រាវបានហៅថា ជា Proto-urban។[២] បន្ទាប់ពីកំណាយនៅទីតាំងស្ថានីយនេះរួច អ្នកស្រាវជ្រាវបានដឹងថាទីតាំងស្ថានីយនេះ ជាទីតាំងដ៏សំខាន់នៅក្នុងតំបន់អាស៊ីកណ្ដាល ដោយបានរកឃើញនូវភស្តុតាងសំខាន់ជាច្រើនដូចជា វត្ថុសិល្បៈអំពីដីដុត (Terracotta)។ អរិយធម៌នេះជាកន្លែងដែលចាប់ផ្ដើម លើការធ្វើពាណិជ្ជកម្ម ជួញដូរ រ៉ែ គ្រឿងបរិភោគផ្សេង និងជាពិសេសភក្កសត្វជាដើម ដែលបណ្ដាប្រទេសនៅក្នុងតំបន់អាស៊ីកណ្ដាល ជាពិសេសជាមួយនឹងឥណ្ឌាស, មេសូម៉ូតាមី ជាដើម។[៣]( រូបលេខ៣-៤)

បន្ទាប់មកនៅក្នុងយុគសំរិទ្ធ, នៅទីតាំងនៃស្ថានីយនេះឃើញមានការប្រើប្រាស់នូវចង្ក្រានក្តសម្រាប់ចម្រាញ់ថ្មរ៉ែដែក ឬចង្ក្រានក្តស្ងដែកសម្រាប់ផលិតឧបករណ៍ដែក។ ឧបរណ៍ដែកទាំងនោះមានដូចជាពូថៅ ចប់ជីក ចប់កាប់ជាដើម ដែលសម្រាប់ប្រើប្រាស់កសិកម្ម

---

[១] https://whc.unesco.org/en/list/1141

[២] https://www.britishmuseum.org/collection/term/x14426

[៣] https://whc.unesco.org/en/list/1141

អត្ថបទដោយ៖ អេង តុលា

និងជីវភាពប្រចាំថ្ងៃ។ ការងារទាំងនោះហៅថា ជាការងារលោហៈកម្ម (metallurgy) ដែលជាផ្នែកមួយនៃរីកសាយភាយវប្បធម៌ **Sarazm** នៅក្នុងតំបន់អាស៊ីកណ្តាល (រូបលេខ៥-៦)។

មនុស្សក្នុងអរិយធម៌នេះមានជំនាញ បច្ចេកទេស ក្នុងឧស្សាហកម្មលោហៈធាតុ និងជាបណ្តាញសម្រាប់ទំនាក់ទំនងជាមួយនឹងអរិយធម៌ផ្សេងៗតាមរយៈការដូរញដូរ វត្ថុសិល្បៈ និងបច្ចេកទេសក្នុងការផលិត។

អ្នកស្រាវជ្រាវពុំបានដឹងអំពីមូលហេតុច្បាស់លាស់ នៃការដួលរលំនៃអរិយធម៌ **Sarazm** នេះទេ ប៉ុន្តែប្រហែលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងមានការឈ្លានពីអរិយធម៌ដទៃទៀត និងមានកត្តាផ្សេងៗដែលធ្វើឱ្យអរិយធម៌ដ៏ចំណាស់ក្នុងតំបន់នេះដួលរលំ។

សរុបមកអរិយធម៌ Sarazm នេះជាអរិយធម៌ដែលមានបច្ចេកទេសខ្ពស់ក្នុងការចម្រាញ់រ៉ែ ដែក និងបច្ចេកទេសផលិតវត្ថុសិល្បៈអំពីដីដុត។ តាមរយៈវត្ថុ និងគ្រោងឆ្អឹងទាំងនោះ បានបង្ហាញថាអរិយធម៌នេះមានឥទ្ធិពលរបស់ខ្លួនរយៈពេលប្រមាណ៤០០០ឆ្នាំមុនគ.ស. ដល់ ៣០០០ឆ្នាំមុនគ.ស.។

## ឯកសារយោង


https://whc.unesco.org/en/list/1141

https://www.britishmuseum.org/collection/term/x14426


អត្ថបទដោយ៖ អេង តុលា



រូបលេខ១ & ២៖ ស្ថានីយ Sarazm

ប្រភព៖ https://whc.unesco.org/en/list/1141/gallery/&maxrows=13




អត្ថបទដោយ៖ អេង តុលា





រូបលេខ៣ &៤ ៖ ស្ថានីយ Sarazm បន្ទាប់ពីកំណាយ
ប្រភព៖ [https://whc.unesco.org/en/list/1141/gallery/&maxrows=13](https://whc.unesco.org/en/list/1141/gallery/&maxrows=13)



រូបលេខ៥ & ៦៖ គ្រោងឆ្អឹង និង វត្ថុសិល្បៈ
ដែលបានរកឃើញកន្លងមក
ប្រភព៖ Unesco.org



អត្ថបទដោយ៖ អេង តុលា